# មេរៀនទី ៤៩៖ ម៉ូសេជួបព្រះនៅឯគុម្ពបន្លាដែលកំពុងឆេះ

## និក្ខមនំ ២៖១១- ៣៖២០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/2aO6f-nL9zQ

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/1oWI-_67XNU

**គោលបំណង៖** ព្រះមានអំណាចអស្ចារ្យ!

**ខគម្ពីរចងចាំ៖ ទំនុកដំកើង ១៤៧៖៥** *"ព្រះអម្ចាស់នៃយើងខ្ញុំទ្រង់ធំប្រសើរ ហើយមានឫទ្ធានុភាពក្រៃលែង ឯប្រាជ្ញាញាណរបស់ទ្រង់ក៏យល់គ្រប់ទាំងអស់"។*

**ចំរៀង** ( *យូធូបលីង* )៖

១.ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

២.ពេលខ្យល់ព្យុះបក់ខ្លាំង https://youtu.be/lI5A7jKQb2o

៣.ខ្ញុំទុកចិត្តដល់ព្រះយេស៊ូវ https://youtu.be/Vq_yln2huAM

## ១. អធិស្ឋាន

## ២. ចំរៀង

*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

## ៣. ល្បែងកំសាន្ត *"ព្រះមានអំណាច"*

សម្ភារៈដែលត្រូវការ៖ ក្រដាស និងខ្មៅដៃមួយចំនួន





១. ចែកកុមារជាក្រុម ដែលក្នុង១ក្រុមៗ អាចមានសមាជិកពី ៣-៤ នាក់។

២. ឲ្យក្រដាសនិងប៊ិចទៅក្រុមនីមួយៗ ហើយឲ្យពួកគេសរសេរនូវអ្វីដែលបង្ហាញថាព្រះជាម្ចាស់មានអំណាច។

៣. ក្រុមដែលសរសេរបានច្រើនជាងគេនិងឈ្នះហ្គេមនេះ! (ចម្លើយ៖ *មហាសមុទ្រ ផ្គររន្ទះ ខ្យល់ព្យុះ កំបុតត្បូង ភ្នំ ថ្ងៃលិច ព្រៃឈើ ការព្យាបាល ការអភ័យទោស និងអ្វីៗជាច្រើនទៀត។* )

## ៤. ការណែនាំមេរៀន

ម៉ូសេធំឡើងនៅក្នុងរាជវាំង បន្ទាប់ពីគាត់ត្រូវបានជួយសង្គ្រោះដោយបុត្រីផារ៉ោនដែលជាព្រះនាងម្ចាស់របស់អេហ្ស៊ីប។ ថ្ងៃមួយម៉ូសេបានឃើញទាហានអេហ្ស៊ីបកំពុងវាយបុរសជនជាតិអ៊ីស្រាអែលម្នាក់។ ទោះបីជាម៉ូសេធំឡើងនៅក្នុងរាជវាំងក៏ដោយ ក៏គាត់ដឹងថាគាត់ជាជនជាតិអ៊ីស្រាអែលដែរ។ គាត់ខឹងខ្លាំងណាស់

ហើយក៏បានសម្លាប់ទាហានអេហ្ស៊ីបនោះ។ ម៉ូសេបានរត់គេចខ្លួនព្រោះស្តេចផារ៉ោនបានដឹងអំពី រឿងនេះ ហើយស្តេចផារ៉ោនចង់សម្លាប់ម៉ូសេវិញ។ ម៉ូសេបានទៅកន្លែងដ៏ឆ្ងាយហើយស្នាក់នៅទីនោះ យ៉ាងយូរ។ ក្នុងពេលនោះដែរ រាស្ត្ររបស់ព្រះក៏នៅតែជាប់ជាទាសករនៅអេហ្ស៊ីបនៅឡើយ ពួកគេបានស្រែកយំទូលអង្វរព្រះឲ្យជួយសង្គ្រោះពួកគេ។ តើអ្នកណាអាចជួយសង្គ្រោះជនជាតិអ៊ីស្រាអែលពីស្តេចអេហ្ស៊ីបបាន?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅស្រុកឆ្ងាយមួយដែលមានឈ្មោះថាម៉ាឌាន កាលម៉ូសេកំពុងឃ្វាលចៀមរបស់គាត់នៅទីនោះ ក៏មានរឿងដ៏អស្ចារ្យមួយបានកើតឡើង។ ព្រះចង់និយាយជាមួយម៉ូសេ ប៉ុន្តែទ្រង់ត្រូវការ ធ្វើឲ្យម៉ូសេ ចាប់-អារម្មណ៍ជាមុនសិន។ ដូច្នេះព្រះបានធ្វើឲ្យគុម្ពបន្លាឆេះដោយអំណាចដ៏អស្ចារ្យរបស់ទ្រង់។ គុម្ពបន្លា បានឆេះមែន ប៉ុន្តែមិនឆេះសុសនោះទេ! ព្រះក៏ទទួលបានការចាប់អារម្មណ៍ពីម៉ូសេ! ព្រះជាម្ចាស់មាន បន្ទូលមកកាន់លោកម៉ូសេពីក្នុងគុម្ពបន្លាថា ឲ្យគាត់ត្រលប់ទៅប្រទេសអេហ្ស៊ីបវិញ ហើយប្រាប់ទៅផារ៉ោនឲ្យដោះលែងរាស្ត្ររបស់ព្រះទៅ។

សំរាប់ម៉ូសេ នេះមិនមែនជាការសម្រេចចិត្តងាយស្រួលទេព្រោះ ផារ៉ោន ចង់សម្លាប់គាត់។ ហើយម៉ូសេក៏មិនប្រាកដចិត្តថា តើប្រជាជនអ៊ីស្រាអែលនឹងស្តាប់តាមគាត់ឬអត់? តែ ម៉ូសេនៅតែស្តាប់បង្គាប់ព្រះ។ ព្រះទទួលការចាប់អារម្មណ៍ពីម៉ូសេដោយអំណាចដ៏អស្ចារ្យ របស់ទ្រង់តាម រយៈគុម្ពបន្លាដែលកំពុងឆេះ។ បន្ទាប់មកអំណាចនៃសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ ទ្រង់បានយកឈ្នះ ចិត្តរបស់ម៉ូសេ។ ហើយប្រាជ្ញាដ៏ខ្លាំងពូកែរបស់ទ្រង់បានធ្វើឲ្យម៉ូសេចង់ស្តាប់តាមបង្គាប់ទ្រង់។ ម៉ូសេបាន ឆ្លើយតបទៅកាន់ព្រះជាម្ចាស់ដោយធ្វើនូវអ្វីគ្រប់យ៉ាងដែលព្រះបានបង្គាប់។ សូមធ្វើឲ្យដូចជាម៉ូសេ ដោយស្តាប់បង្គាប់ព្រះ ព្រោះព្រះរបស់យើងទ្រង់អស្ចារ្យ!

## ៦. សំនួរពិភាក្សា

១.តើម៉ូសេបានឃើញអ្វីនៅខាងក្រៅរាជវាំង?( *ទាហានអេហ្ស៊ីបម្នាក់វាយបុរសជនជាតិអ៊ីស្រាអែលម្នាក់*)
២.តើផារ៉ោនចង់ធ្វើអ្វីនៅពេលគាត់ដឹងថាម៉ូសេសម្លាប់ទាហានអេហ្ស៊ីប?( *ផារ៉ោនចង់សម្លាប់ម៉ូសេ*)
៣.តើព្រះបានធ្វើអ្វីដើម្បីធ្វើឲ្យម៉ូសេចាប់អារម្មណ៍លើទ្រង់?( *ទ្រង់ដុតគុម្ពបន្លាប៉ុន្តែគុម្ពបន្លាមិនឆេះសុសនោះទេ*)
៤.តើព្រះចង់ឲ្យម៉ូសេធ្វើអ្វីសំរាប់ជនជាតិអ៊ីស្រាអែល? *(ត្រឡប់ទៅអេហ្ស៊ីបវិញហើយជួយសង្គ្រោះជនជាតិអ៊ីស្រាអែលពីភាពជាទាសករ)*
៥.តើប្អូនគិតថា ព្រះកំពុងប្រើប្អូនធ្វើអ្វីខ្លះដើម្បីជួយដល់ក្រុមគ្រួសារ សហគមន៍និង អ្នកដទៃ?
*(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

## ៧. ល្បែងកំសាន្ត *"ព្រះយេស៊ូវបញ្ជា"*

**របៀបលេង**: យើងលេងល្បែងព្រះយេស៊ូវបញ្ជាដោយគ្រូដើរតួធ្វើជាព្រះយេស៊ូវ នៅពេលដែលកុមារឮពាក្យ "ព្រះយេស៊ូវបញ្ជា" កុមារត្រូវធ្វើតាមអ្វីដែលគ្រូបានប្រាប់ដូចជា ប៉ះក្បាល លោតឡើង សើច...។ បើអត់ឮពាក្យ "ព្រះយេស៊ូវបញ្ជា" កុមារមិនត្រូវធ្វើតាមឡើយ។ពេលខ្លះគ្រូអាចព្យាយាមធ្វើបន្លំឲ្យកុមារ ធ្វើ

ខុសតាមដែរ ដោយគ្រូធ្វើកាយវិការតែអត់ស្រែកថា "ព្រះយេស៊ូវបញ្ជា" ទេ។

## ៨. ខគម្ពីរចងចាំ

**ទំនុកដំកើង ១៤៧:៥** *"ព្រះអម្ចាស់នៃយើងខ្ញុំទ្រង់ធំប្រសើរ ហើយមានឫទ្ធានុភាពក្រៃលែង ឯប្រាជ្ញាណរបស់ទ្រង់ក៏យល់គ្រប់ទាំងអស់។"*

សូមជួយកុមារឲ្យចងចាំខគម្ពីរនេះ។

## ៩. ហត្ថកម្ម



យកក្រដាសមួយបត់វាជាពីរហើយកាត់ជាការ៉េនៅចំកណ្តាល រួចហើយយកក្រដាសនោះមកស៊កលើក្បាលនិងខ្លួនទាំងអស់គ្នា ហើយសួរកុមារថា តើគេគិតថាក្រដាសរាងការ៉េនេះអាច ស៊ក ក្បាលនិងខ្លួនពួកគេចូលដែរឬទេ? កុមារនឹងនិយាយថាគេស៊កមិនចូលនោះទេ ពីព្រោះការ៉េតូចពេក។



បន្ទាប់មកកាត់ក្រដាសដែលបត់ដូចបង្ហាញនៅរូបខាងស្តាំ។ បន្ទាប់ពីបានកាត់រួចហើយ សូមលាតក្រដាសនោះឲ្យអស់។ ឥឡូវនេះសូម សួរកុមារថាតើពួកគេគិតថាពួកគេអាចស៊កក្បាល និងខ្លួននឹងក្រដាសនេះ បានដែរឬទេ?ត្រូវហើយខ្ញុំអាចស៊កវា បានព្រោះវាធំ។

ទោះបីជានៅក្នុងជីវិត រឿងខ្លះហាក់ដូចជាមិនអាចទៅរួចក៏ដោយ តែជាមួយនឹងអំណាចរបស់ព្រះអ្វីក៏អាចទៅរួចដែរ!

## ១០. ចំរៀង *សូមរើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូះ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
មនុស្សជាច្រើនមានបញ្ហាជាមួយអារម្មណ៍ដែលគ្មានប្រយោជន៍។ អរព្រះគុណព្រះយេស៊ូវដែលបាន ប្រើអស់អ្នកដែលស្ម័គ្រចិត្តធ្វើតាម និងបំរើទ្រង់។ ម៉ូសេមានការសង្ស័យអំពីខ្លួនគាត់ប៉ុន្តែគាត់បានទទួលយកថា ព្រះបានជ្រើសរើសគាត់សម្រាប់កិច្ចការពិសេសមួយនេះ។ តើអ្នកធ្លាប់បរាជ័យ ឬមានបទពិសោធន៍ថាអ្នកភយ័ខ្លាចដែលអ្នកត្រូវដកហូតសិទ្ធិពីការបម្រើព្រះពេញលេញទេ? សារភាពពីការខ្វល់ខ្វាយរបស់អ្នកទៅកាន់ព្រះ ហើយអនុញ្ញាតឱ្យទ្រង់លើកទឹកចិត្តអ្នកដោយសេចក្តីពិតៈ ព្រះនឹងប្រើអ្នកណាដែលស្ម័គ្រចិត្តបម្រើ។ កូនសូមអរគុណដែលបានបម្រើរាស្ត្ររបស់ព្រះអង្គ!